# កំណត់សំគាល់អំពីការបង្កើតពាក្យថ្មីក្នុងភាសាខ្មែរ [១]

*ដោយ សុខ-ផល*
*សកលវិទ្យាល័យម៉ុងរ៉េអាល់*

ប្រទេសកម្ពុជាបានជួបវិបត្តិផ្នែកភាសាមួយគ្រាមកហើយ *កាលដែលបានទទួលឯករាជ្យពីប្រទេសបារាំង ក្នុងកំលុងឆ្នាំ ១៩៥០ ។ គ្រានោះ គំនិតស្នេហាជាតិបានកើតឡើងយ៉ាងពេញទំហឹង ។ គេសំរេចចិត្តប្តូរពាក្យបារាំងដែលធ្លាប់ប្រើក្នុងរដ្ឋបាល ប្រព័ន្ធយុត្តិធម៌ និង សិក្សាធិការជាតិ ដោយប្រើពាក្យខ្មែរជំនួសវិញ ។ ដើម្បីសំរេចការនេះ គេបានបង្កើតគណៈកម្មការវប្បធម៌មួយ ដើម្បីធ្វើការបង្កើតពាក្យថ្មី នាឆ្នាំ ១៩៤៦ ។ អ្នកចូលរួមក្នុងគណៈកម្មការវប្បធម៌សុទ្ធសឹងជាព្រះសង្ឃដែលមានចំណេះខ្ពង់ខ្ពស់ផ្នែកភាសាបាលី ។ កិច្ចចំបងរបស់គណៈកម្មការវប្បធម៌ គឺត្រូវបកប្រែពាក្យបារាំងទាំងអម្បាលម៉ានដែលធ្លាប់មានប្រើក្នុងភាសាខ្មែរ ។ ភាសាវិទូបារាំងដ៏ល្បីល្បាញម្នាក់ ឈ្មោះ ហ្វ្រង់ស្វ័រ-ម៉ាកទីនី បានចូលរួមធ្វើការជាមួយគណៈកម្មការវប្បធម៌នេះ គឺរវាងឆ្នាំ ១៩៤៦ ដល់ ១៩៥០ ។ លោកបានធ្វើការកត់សំគាល់របៀបរបបដែលខ្មែរធ្វើការក្នុងការបង្កើតពាក្យថ្មី ។ លោក ម៉ាកទីនី សរសេរក្នុងអត្ថបទមួយមានចំណងជើងថា* “De la création actuelle des mots en cambodgien” *«[អំពីវិធីបង្កើតពាក្យថ្មីនាបច្ចុប្បន្នក្នុងភាសាខ្មែរ]» (ម៉ាកទីនី ១៩៦២) ។*

*លោកបានបញ្ជាក់ពីរបៀបគណៈកម្មការវប្បធម៌ធ្វើ មានវិធីបង្កើតពាក្យថ្មីដូចខាងក្រោមនេះ ÷*

*១-បង្កើតន័យថ្មីរបស់ពាក្យខ្មែរដែលមានស្រាប់ ឬ ន័យធៀបរបស់ពាក្យនោះ*

*ឧ. ១* កង់ *«ប្រដាប់រទេះមានរង់ព័ទ្ធជុំវិញចុងកាំ» (***វចនានុក្រមខ្មែរ** *របស់សម្តេចព្រះសង្ឃរាជ ជួន-ណាត តទៅនេះ ហៅខ្លីថា ជ.ណ.) >* កង់ *«យានកង់ពីរដែលអាចប្រព្រឹត្តទៅមុខ បានដោយសារឈ្នាន់, ច្រវាក់ថាស ជាដើម ដែលជាក់ទាក់ទងគ្នាជាមួយនឹងដុំកង់នៃកង់ក្រោយនិងដុំកណ្តាល» (ជ.ណ.) ។*

*១* គ្រាប់ *«ពូជកើតក្នុងផ្លែមានសណ្ឋានផ្សេងៗ» (ជ.ណ.) >* គ្រាប់ *«ដុំមូលធ្វើដោយលោហជាតិផ្សេងៗ មានសំណជាដើមសម្រាប់ច្រកក្នុងកាំភ្លើង ហើយបាញ់» (ជ.ណ.) ។ បន្ទាប់មក ក៏បង្កើតពាក្យ* គ្រាប់បែក គ្រាប់បែកដៃ *។ល។*

*២-រក្សាពាក្យបារាំងដែលខ្មែរទូទៅធ្លាប់យកមកប្រើរត់មាត់ ហើយដែលមានសំនៀងងាយថាតាមស្តាប់ស្រួល*

*ឧ. ១* ប៉ុយរ៉ូ ប៉ុស្តិ៍ តែម ប៉ូលិស អូតែល ... ។

៣-កម្ចីដោយប្រែពាក្យមួយទៅពាក្យមួយទៀត ពីភាសាបារាំងផ្ទាល់

ឧ. ◎ ទេសចរ (សំ. ទេឝ, បា. ទេស «ប្រទេស; ភូមិ» + សំ. បា. ចរ «ត្រាច់, ដើរ, ទៅ; ប្រព្រឹត្ត») (< touriste) ។

◎ ទូរស័ព្ទ (សំ. បា. ទូរ «ឆ្ងាយ» + សំ. ឝព្ទ (បា. សទ្ទ) «សំឡេង, សម្ដី») (< téléphone)... ។

គួរសំគាល់ថា យើងបង្កើតពាក្យទាំងពីរខាងលើ ដោយប្រើធាតុពីបាលីសំស្ក្រឹត ។ ខាងក្រោមនឹងបានឃើញគេបង្កើតពាក្យតាមវិធីដដែល ដោយប្រើពាក្យខ្មែរ ។

៤-កម្ចីផ្ទាល់ពីបាលីសំស្ក្រឹត ឬ ពាក្យផ្គុំដែលកើតឡើងដោយសារធាតុបាលីសំស្ក្រឹត

ឧ. ◎ សេរីភាព (បា. សេរ «សិទ្ធិឬអំណាចលើខ្លួន» + ឦ (បច្ច័យ) + សំ. បា. ភាវ «ភាវៈ; បែប, បែបបទ; លំនាំ, លំនាំសមសា, ឫកពា; ទម្រង់, សណ្ឋាន, ទ្រង់ទ្រាយ; ភេទ») ។

ក្នុងអត្ថបទដដែលនោះ លោក ម៉ាកទីនី មិនបានលើកពីវិធីបង្កើតពាក្យតាមរបៀបផ្សំខ្មែរទេ គឺបទភ្ជាប់ ។ ខ្ញុំសូមសន្មតហៅថាវិធីទី ៥ ហើយនឹងលើកយកមកសិក្សាវិភាគដោយសង្ខេប ក្នុងផ្នែកចុងក្រោយនៃអត្ថបទនេះ ។

ក្រោយពេលប្រទេសកម្ពុជាបានបើកចំហផ្នែកសេដ្ឋកិច្ច ឆ្ពោះទៅរកទីផ្សារសេរី ធ្វើការផ្លាស់របបនយោបាយឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ កំលុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបច្ចុប្បន្នត្រូវប្រឈមមុខនឹងវិបត្តិភាសាជាថ្មីម្ដងទៀត គឺគេត្រូវប្រែពាក្យបរទេសទាំងឡាយ ដែលហូរចូលក្នុងភាសាខ្មែរ បង្កើតពាក្យថ្មីក្នុងវិស័យផ្សេងៗ ដូចជា បច្ចេកវិទ្យាជាន់ខ្ពស់ ពត៌មានវិទ្យា អេឡិចត្រូនិចបរិស្ថាន ច្បាប់ រដ្ឋបាល ប្រជាធិបតេយ្យូបនិយកម្ម វិស័យទេសចរ អប់រំ ។ល។

គោលបំណងចំបងនៃអត្ថបទនេះ គឺ សិក្សាការបង្កើតពាក្យថ្មីក្នុងភាសាខ្មែរ ក្រោយរយៈជាងកន្លះសតវត្សរ៍ ។ តើភាសាខ្មែរមានបួនវិធីបង្កើតពាក្យថ្មី ឬ យ៉ាងដូចម្ដេច ? តើវិធីបង្កើតពាក្យថ្មីនាបច្ចុប្បន្ន មានទំនោរ និង សណ្ឋានបែបផ្សេងឬទេ ? ខ្ញុំសាកល្បងឆ្លើយសំណួរខាងលើ ព្រមទាំងបង្ហាញពីចំណាប់អារម្មណ៍ខ្លះៗ ពីសំណាក់អ្នកនិយាយភាសាខ្មែរ ចំពោះវិធីបង្កើតពាក្យថ្មីនេះ ។ ដើម្បីសំរួលកិច្ចនេះ ខ្ញុំនឹងរក្សាលំដាប់របស់លោក ម៉ាកទីនី ដូចបានពោលរួចខាងលើស្រាប់ ។ ដោយពាក្យថ្មីទាំងឡាយ ពុំមានចុះក្នុង **វចនានុក្រមខ្មែរ** របស់សម្ដេចព្រះសង្ឃរាជ ជួន-ណាត (ជ.ណ.) ខ្ញុំសូមឲ្យនិយមន័យបណ្ដោះអាសន្នជាសេចក្ដីពន្យល់ តាមគំនិត និង ចំណេះដឹងផ្ទាល់ខ្លួន ដួនកំផ្អែកលើនិយមន័យពីភាសាបរទេស ។ ដូច្នេះ ប្រាកដជាមានកង្វះខាត ឆ្គាំឆ្គង ភាន់ច្រឡំ ដោយប្រការណាមួយមិនខាន ។ រំពឹងថា ថ្ងៃណាមួយ ខ្មែរនឹងមានលទ្ធភាពបង្កើតគណៈកម្មការវប្បធម៌ជាតិមួយ រួមគ្នាចងក្រងពាក្យថ្មី តាមក្បួនខ្នាតវិទ្យាសាស្ត្រទំនើប ទុកជាកេរដំណែលដល់កូនចៅជំនាន់ក្រោយ ។

## ១-បង្កើតន័យថ្មីរបស់ពាក្យខ្មែរដែលមានស្រាប់ ឬ ន័យធៀបរបស់ពាក្យនោះ

*ពាក្យដែលគួរឲ្យចាប់អារម្មណ៍មុនគេនោះ គឺ ពាក្យ* ជជុះ *ដែលមានន័យដើមថា «រលាស់ឲ្យជ្រុះ» (វ.ណ.) ក្លាយជាមានន័យថា «របស់អ្វីដែលចាស់មិនថ្មី គេប្រើរួច» ។*

*ឧ.* ១ ខោអាវជជុះ ម៉ូតូជជុះ ឡានជជុះ *(នៅពេលប្រទេសកម្ពុជាបើកឲ្យនាំចូលរបស់ចាស់ កំលុងឆ្នាំ ១៩៨០) ពាក្យជជែលនេះ ក៏បែកន័យថ្មីផ្សេងទៀតដូចជា ÷*

*ឧ.* ១ កុងត្រូលជជុះ អាណិកជនជជុះ *(កំប៉ិកកំប៉ុក ខុសច្បាប់ ធុនទាប) ។*

*ពាក្យមួយផ្សេងទៀត* ស្រោម *មានន័យដើមថា «១-វត្ថុសម្រាប់ស្រោបឱបពីខាងក្រៅ ដើម្បីការពារមិនឲ្យសៅហ្មង ឬ ឲ្យកំបាំង ឲ្យស្រួលចាប់កាន់ ឲ្យល្អមើល; ២-ថង់ជើង ឬ ដៃ» (វ.ណ.) ។ មានន័យដូចក្នុងពាក្យ* ស្រោមខ្នើរ ស្រោមអនាម័យ *... ។*

១ អាវភ្លៀង *«សំពត់ពាក់ដណ្ដប់រាងកាយទាំងមូល មានទាំងគំរបក្បាលទៀតផង ច្រើនធ្វើពីជាតិកៅស៊ូ ពាក់ការពារកុំឲ្យទទឹកភ្លៀង»* ន័យថ្មីមួយទៀតរបស់ពាក្យនេះ *សំដៅលើ «ស្រោមកៅស៊ូស្តើងថ្លា បំពាក់គ្រឿងលិង្គបុរស ពេលរួមភេទបង្ការជំងឺអេដស៍» ។*

*ពាក្យថ្មីផ្សេងៗ ទៀត រួមមាន ÷ ដាក់កង សៀវភៅផ្នត់ ទ្រុងជ្រូក កាប់ដាវ ដែលខ្ញុំនឹងអធិប្បាយហូរហែខាងក្រោមនេះ ។*

១ *ដាក់កង ពាក្យ* កង *មានពន្យល់ដូចតទៅ ÷*

*«កងប្រដាប់មានវង់មូល សម្រាប់ពាក់ប្រហក ÷ កងដៃ កងជើង កងក្រវិល» (វ.ណ.) ។*

*ពាក្យ* កង *គឺសំដៅឧបករណ៍វេជ្ជសាស្ត្រ មានសណ្ឋានដូចកង ដែលបំពាក់ក្នុងប្រដាប់បន្តពូជស្ត្រីក្នុងបំណងពន្យារកំណើត ។ មានប្រើច្រើននាពេលបច្ចុប្បន្ន ។ គួរកត់សំគាល់ថា ឧបករណ៍នេះភាគច្រើនមានទំរង់ជាកង តែមិនមែនទាំងអស់នោះទេ ។*

១ *សៀវភៅផ្នត់ ពាក្យ* ផ្នត់ *មានពន្យល់ដូចតទៅ ÷*

*«ស្នាមដែលបត់សំណុំ ឬ ដុំអ្វីៗ ដែលបត់ ÷ ផ្នត់ពោះ ផ្នត់សំពត់ សំពត់ ២ ផ្នត់» (វ.ណ.) ។*

*គឺសៀវភៅខ្នាតតូច ឬ ស្តើងដែលរដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាល រៀបចំឡើង ដើម្បីចែកចាយដល់អ្នកស្រុក ក្នុងបំណងផ្សព្វផ្សាយអប់រំ ។ល។*

១ *ទ្រុងជ្រូក ពាក្យ* ទ្រុង *មានពន្យល់ដូចខាងក្រោម ÷*

*«ប្រដាប់សម្រាប់ដាក់ សម្រាប់ប្រុស សម្រាប់ខាំងសត្វទាំងឡាយ ÷ ទ្រុងលលក ទ្រុងមាន់ ទ្រុងត្រី ទ្រុងខ្លា ជាដើម» (វ.ណ.) ។ វចនានុក្រមខ្មែរពុំបានចុះពាក្យទ្រុងជ្រូកជាមួយឧទាហរណ៍ខាងលើទេ តែជាពាក្យសាមញ្ញ ដែលគេសំដៅលើទ្រុងសម្រាប់ដាក់ជ្រូក ដូចសត្វដទៃទៀតដែរ សព្វថ្ងៃសម័យទូរស័ព្ទដៃគ្រប់គ្នា គេប្រើពាក្យនេះ សម្រាប់សំគាល់សញ្ញា # ដែលមានចារនៅលើធ្នុចផ្សេងៗ ដើមហេតុប្រហែលជារូបសញ្ញានេះ វាមានទំរង់ស្រដៀងទៅនឹងទ្រុងជ្រូកនេះឯង ។*

១ *កាប់ដាវ ពាក្យ* កាប់ *មានពន្យល់ដូចខាងក្រោម ÷*

*«ប្រហារដោយគ្រឿងមានមុខមុត មានដាវ និង កាំបិត ជាដើម» (វ.ណ.) ។*

*បន្ទាប់មក នាទសវត្សរ៍ទី ១៩៦០-៧០ មានភាពយន្តចិនយ៉ាងសន្ធឹកណាស់ ផ្នែកវាយប្រហារគ្នាដោយដាវ បានហូរចូលមកស្រុកខ្មែរ ដែលគេតែងហៅថា រឿងកាប់ដាវ ឬ កុនកាប់ដាវ ។ ន័យថ្មីរបស់* កាប់ដាវ *សំដៅលើអសម្មាអាជីព ឬ អសម្មាអាជីវៈ អសីលធម៌ ដែលគេឃើញកើតមានជាប្រចាំក្នុងសង្គមខ្មែរបច្ចុប្បន្ន រួមមានកេងប្រវ័ញ្ច ឆបោក ជិះជាន់ ធ្វើបាប កុហក បំពានច្បាប់ ហើយចំពោះមនុស្សគ្រប់រូបមិនរើសមុខ អាចជាញាតិខ្លួនមិត្តខ្លួន ។ល។*

*ពាក្យកំណាព្យខ្មែរសម័យមុន ថ្លែងថា ÷ «តូចស៊ីដោយតូច ធំស៊ីដោយធំ» តែន័យ* កាប់ដាវ *ពេលនេះ គឺ ស៊ីទាំងតូចទាំងធំ ! ។*

## ២-កម្ចីពីភាសាបារាំង ឬ អង់គ្លេស

*ពាក្យបារាំងដែលខ្មែរទូទៅ ធ្លាប់យកមកប្រើរត់មាត់ ហើយដែលមានសំនៀងងាយថាតាមស្ដាប់ស្រួល គេនៅរក្សាប្រើរហូតមក ។ ខ្មែរនៅតែបន្តខ្ចីពាក្យបារាំងខ្លះទៀត ព្រោះនៅមានអ្នកចេះភាសាបារាំងថ្មីក វ័យចំណាស់ខ្លះ ចេះតែយកពាក្យពេចន៍បារាំង មកប្រើជារឿយៗ ។ ប៉ុន្តែ ថ្មីៗនេះ ខ្មែរបានងាកទៅខ្ចីពាក្យពីភាសាអង់គ្លេសយ៉ាងសន្ធឹកសន្ធាប់ ។ អ្នកណាក៏បានដឹងឮពីសម័យអន្តរកាលនេះដែរ ដូចមានការប្រើពាក្យបារាំង និង អង់គ្លេសក្នុងពេលជួនគ្នា ។*

ខ.១ ស៊ីដា ឬ អេដស៍ ។

១ អរឌីណាទ័រ ឬ កុំព្យូទ័រ ។

*តើមូលហេតុអ្វីខ្លះ ដែលជំរុញឲ្យខ្មែរងាកទៅប្រើពាក្យអង់គ្លេសយ៉ាងសន្ធឹកសន្ធាប់ដូច្នេះ ? មានកត្តាផ្សេងៗ ដែលជំរុញឲ្យមានការផ្លាស់ប្ដូរនេះ គឺជាបឋម ប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការអាស៊ាននាឆ្នាំ ១៩៩៩ ដែលប្រទេសសមាជិកនៃអង្គការនេះ ប្រើអង់គ្លេសរួមគ្នា ។ រឿងមួយទៀត គឺការវិលត្រឡប់ជារឿយៗ របស់បងប្អូនខ្មែរ ដែលរស់នៅឯបរទេស ជាពិសេសពីប្រទេសដែលប្រើភាសាអង់គ្លេសជាផ្លូវការ រួមមាន ÷ អូស្រ្ដាលី កាណាដា សហរដ្ឋអាមេរិក ។ ជាងនេះទៅទៀត អង្គការក្រៅរដ្ឋាភិបាលដ៏សន្ធឹកណាស់ ដែលមានទីតាំងប្រចាំនៅកម្ពុជា ភាគច្រើនប្រើភាសាអង់គ្លេសជាផ្លូវការ ។ ឯកត្តាចំបងនោះ គឺ កត្តាសេដ្ឋកិច្ច ។ លោក ក្លៃតុន (២០០២) បានលើកឡើងពីស្ថានភាពភាសាក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន គឺថា យុវជនខ្មែរខិតខំរៀនភាសាអង់គ្លេសស្ទើរតែគ្រប់រូបក្នុងបំណងងាយស្រួលស្វែងរកការងារ ។ ចំនួនអ្នកសិក្សា កើនឡើងជាលំដាប់ ។ គឺអ្នកចេះភាសាអង់គ្លេសទាំងនេះហើយ ដែលខ្ចីពាក្យអង់គ្លេស យកមកប្រើក្នុងភាសាខ្មែរយើង ។ ពាក្យអង់គ្លេសខ្លះ ត្រូវគេនិយមប្រើមួយគ្រា ក៏សាបរលាបទៅវិញ ខ្លះក៏នៅប្រើជាប់ជាដរាបមក ។ ពាក្យអង់គ្លេសមួយចំនួនដែលគេប្រើរត់មាត់ ហើយនឹងអាចក្លាយជាកម្ចីដូចជា ÷* ប្រ៊ីកហ្វឹស *(បាយព្រឹក)* ឌិនណឺ *(បាយល្ងាច) ... ។ អ្នកវិភាគភាសាខ្មែរខ្លះ (ឈៀង-វិបុល ២០០៣) ធ្វើការទិតៀនការប្រើពាក្យអង់គ្លេសនេះយ៉ាងខ្លាំងក្លា ព្រមទាំងសូមឲ្យប្រើពាក្យ «ខ្មែរ» ដែលមានស្រាប់ជំនួសវិញ ÷* បាតរាស សាយមាស *... ។ សូម*

*បញ្ជាក់ផងដែរថា តាមពិត ពាក្យប៉ុន្នានម៉ាត់នេះ ខ្មែរបានខ្ចីពីបាលី ហើយប្រហែលធ្លាប់បានប្រើមែន តែមិនមានការគាំទ្រពីអ្នកប្រើ ក៏សាបរលាបបាត់អស់ទៅវិញ ។*

*ខាងក្រោម ជាពាក្យពេចន៍ពីភាសាអង់គ្លេសមួយចំនួន ដែលខ្មែរកំពុងពេញនិយមប្រើនាបច្ចុប្បន្នកាលនេះ ។*

*ឧ.* ១ ឌីជេ (< Disc Jockey), ហេរ៉ូអ៊ីន ឬ អេរ៉ូអ៊ីន (< heroin), អ៊ីមែល (< e-mail), អេដស៍ (< Aids), ហ៊ីវ (< HIV), ស្ញូ (<show), ខន់សឺត (<concert), ឌីជីថល (<digital), ដាយណូស័រ (< dinosaur), ម៉ាស្ទ័រ (< master), អិនជីអូ (< non-governmental organization), ហ្គេះហៅ (< guest-house), កូតា (< quota), ម៉ៅ (< mouse), បាកូត (< barcode) *(ពាក្យនេះ បើពិនិត្យតាមច្បាប់សូរសាស្ត្រ ទំនងជាមកពីភាសាបារាំង តែបើពិនិត្យតាមច្បាប់រូបសាស្ត្រវិញ គួរជាពាក្យអង់គ្លេស តាមពិត ទៅជាពាក្យអង់គ្លេសពិត តែខ្ចីតាមអក្ខរាវិរុទ្ធបារាំង)*, វីអាយភី (< VIP), កុំព្យូទ័រ (< computer), អ៊ីនធឺណែត, (<internet), វ៉ែបសាយ (< website), ស្លែដ៍ (< slide), ឡេស៊ែរ (< laser), អេច្ឆអាយវី ឬ ហ៊ីវ (< HIV) ... ។

*គួរកត់សំគាល់ថា ពាក្យខ្លះពុំមានសូរសៀងពិតនៅឡើយ ពិសេសចំពោះពាក្យពហុព្យាង្គ ដូចជា ÷* កុំព្យូទ័រ អ៊ីនធឺណែត វ៉ែបសាយ ... ។

## ៣-កម្ចីដោយប្រែពាក្យមួយទៅពាក្យមួយទៀត ពីភាសាលោកខាងលិច

*កម្ចីបែបនេះ ធ្វើឡើងដោយប្រែពាក្យមួយទៅពាក្យមួយទៀត ពីភាសាបរទេសមកជាភាសាខ្លួន ។ ភាសាខ្មែរធ្លាប់ខ្ចីពាក្យរបៀបនេះ ពីភាសាលោកខាងលិច* មានជាអាទិ៍ *ភាសាបារាំង ឬ អង់គ្លេស ក៏នៅរក្សាវិធីដដែលដែរ ។*

*ឧ.* ១ សញ្ញាភ្លើងខៀវ = *ការអនុញ្ញាត ឬ បទបញ្ជា ដើម្បីអាចប្រតិបត្តិកិច្ចការណាមួយ* (< feu vert, green light *ឬ* go-ahead) *។*

១ បញ្ជីខ្មៅ = *បញ្ជីឈ្មោះមនុស្សទាំងឡាយ ដែលគេស្រង់ទុក និង គួរតែទទួលទណ្ឌកម្ម* (< liste noire, black list) *។*

១ ផ្សារងងឹត = *ការជួញដូរទំនិញដោយខុសច្បាប់ រួមមានតំឡៃ និង បរិមាណ* (< marché noir, black market) *។*

១ តុមូល = *ជំនុំដើម្បីដដែកវែកញែកលើមូលបទមួយក្រៅផ្លូវការ* (< table ronde, round table) *។*

*ចាប់តាំងពីភាសាខ្មែរខ្ចីពាក្យពីភាសាអង់គ្លេស កាន់តែច្រើនទៅៗ ដូចដែលខ្ញុំបានលើកមកវែកញែកក្នុងចំណុចទី ២ កម្ចីដោយប្រែពាក្យមួយទៅពាក្យមួយទៀត ពីភាសាអង់គ្លេស ក៏កាន់តែកើនឡើងដែរ ។*

ឧ. ⊙ គេហទំព័រ = ទំព័រដំបូងនៃវិបសាយទាំងឡាយ ដែលគេស្វាគមន៍អ្នកចូលមើល ផ្ដល់ពត៌មានទូទៅពីវិបសាយនោះ ព្រមទាំងឈ្មោះម្ចាស់ទំព័រទៀតផង (< home page) ។

⊙ ទំព័រលឿង = សៀវភៅចុះលេខទូរស័ព្ទអ្នកស្រុក ផ្នែកផ្សេងទៀត មានរាយនាមផ្សព្វផ្សាយក្រុមហ៊ុននានា (< yellow pages) ។

⊙ មនុស្សខ្លាំង = មេដឹកនាំដែលដណ្ដើមអំណាចដោយកម្លាំងទ័ព និង ការកៀបសង្កត់ផ្សេង ៗ (< strongman) ។

⊙ អង្គការក្រៅរដ្ឋាភិបាល, អង្គការមិនមែនរដ្ឋាភិបាល = អង្គការរដ្ឋបាលឯកច្ឆន្ទទាំងឡាយ ដែលមិននៅក្រោមឱវាទរដ្ឋាភិបាល (< non-governmental organization) (ពាក្យសាមញ្ញ ច្រើនហៅខ្លីថា អង្គការ ៗ) ។

តាំងពីស្រុកខ្មែរមានសន្តិសុខ និង បើកចំហ វិស័យទេសចរណ៍ក៏បានចំរើនឡើងវិញ ។ កម្ពុជាត្រូវប្រឈមមុខនឹងការហូរចូលមកនៃភ្ញៀវទេសចរ ជាពិសេសការទទួលឲ្យស្នាក់នៅ មានសណ្ឋាគារតូចធំ ផ្ទះដួល និង ផ្ទះភ្ញៀវ ។

⊙ ផ្ទះភ្ញៀវ = ផ្ទះទទួលភ្ញៀវទេសចរឲ្យស្នាក់នៅ មានទម្រង់ដូចសណ្ឋាគារ តែតូចជាងនិងថោកជាង (< guest-house) ។ សព្វថ្ងៃ មិនសូវប្រើ ច្រើនហៅ ផ្ទះសំណាក់ វិញ ។

បន្ទាប់មក ការផ្លាស់មុខមាត់ថ្មីនៃសង្គមខ្មែរ ក៏មានលេចចេញនូវការនាំចូលការសេព ការធ្វើពាណិជ្ជកម្មគ្រឿងញៀន បង្កើតបានជាហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង គឺ ពួកបងតូចបងធំ ។

⊙ បងធំ = អ្នកខ្លាំងដោយកំណាចកំឡាំង ជិះជាន់ធ្វើបាបជំរិតយកលុយអ្នកទន់ខ្សោយ មានបង្ខំឲ្យអ្នកទន់ខ្សោយប្រព្រឹត្តអំពើចោរកម្មជួញដូរគ្រឿងញៀន ។ល។ (< big brother) ។

## ៤-កម្ចីផ្ទាល់ពីបាលីសំស្ក្រឹត ឬ ពាក្យផ្គុំដែលកើតឡើងដោយសារធាតុបាលីសំស្ក្រឹត

បច្ច័យ និង បុព្វបទ ដែលលោក ម៉ាកទីនី លើកយកមកសិក្សាក្នុងអត្ថបទរបស់លោក នៅមានគេប្រើញឹកញាប់នៅឡើយ ដូចជា ÷ -ការ -ភាព ឬ ភាព- -ធម៌ -កម្ម -កិច្ច -និយម -សាស្ត្រ -វិទ្យា ។ល។

ចំពោះបច្ច័យ -សាស្ត្រ ឬ -វិទ្យា ខ្មែរយើងនិយមប្រើជំនួសគ្នាទៅវិញទៅមក ដូចជា ភូមិសាស្ត្រ និង ភូមិវិទ្យា ប៉ុន្តែ ពេលខ្លះ គេប្រើបច្ច័យទាំងពីរក្នុងន័យផ្សេងគ្នាដែរ ដូចជា រូបសាស្ត្រ សំដៅទៅលើ «ការសិក្សាមូលភាពនៃការបង្កើតពាក្យ មានពាក្យផ្សំ និង ពាក្យផ្គុំ» ឯ រូបវិទ្យា សំដៅទៅលើ «ការសិក្សាលក្ខណៈទូទៅរបស់ធាតុផ្សេង ៗ» ទៅវិញ ។

លោក ឃីន-សុខ (១៩៩៩: ៣១០ ជើងទំព័រ ៥៦) បានបញ្ជាក់យ៉ាងច្បាស់ថា បច្ច័យទាំងនេះ មានប្រើក្នុងភាសាខ្មែរយូរមកហើយ គណៈកម្មការវប្បធម៌គ្រាន់តែយកបច្ច័យដែលមានស្រាប់ទាំងនោះមកប្រើឡើងវិញប៉ុណ្ណោះ ។

*ខាងក្រោមនេះ ពាក្យថ្មីដែលបង្កើតឡើងដោយប្រើបច្ច័យ ជាឧទាហរណ៍ ÷*

*-ការ*

⊙ ពហិការ = *ការបដិសេធរួមមួយ មិនចូលរួមក្នុងអង្គប្រជុំ ការសំរេចកិច្ចផ្សេងៗ ជាផ្លូវការ ក្នុងបំណងទាមទារការធ្វើសម្បទានពីភាគីម្ខាងទៀត (សម-ថាំង ១៩៦១: ១១០; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ១៣៤) (សំ. ពហិស៑, បា. ពហិ «ក្រៅ, ខាងក្រៅ» + សំ. កាយ៌, បា. ការ «កិច្ច ឬ អំពើដែលត្រូវធ្វើ» > ពហិការ «ដែលគេត្រូវបណ្តេញចេញ») ។*

⊙ វិមជ្ឈការ = *ផ្ទេររំលែកតំណែងអំណាចខ្លះពីរាជធានី (ឬ ទីស្នាក់កណ្តាលណាមួយ) ទៅកាន់ខេត្តស្រុកនានា (សម-ថាំង ១៩៦១: ២១៦; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ៣០១; វ. គោវិទ ១៩៦៧: ៣០៤) (សំ. បា. វិ «គ្មាន, ខ្វះ» + បា. មជ្ឈ (សំ. មធ្យ) «កណ្តាល» + បា. ការ) ។*

*-ភាព ឬ ភាព-*

⊙ និទណ្ឌភាព = *ការដែលមិនចោទប្រកាន់ផ្តន្ទាទោសដល់ជនប្រព្រឹត្តខុសច្បាប់ (សម-ថាំង ១៩៦១: ៤៤៣; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ៦៤៩) (សំ. បា. និ «គ្មាន, ខ្វះ» + សំ. បា. ទណ្ឌ «ដំបង; ឈើច្រត់; កំណាត់ឈើ; អាជ្ញា; ទោស, កំហុស» + សំ. បា. ភាវ) ។*

⊙ តម្លាភាព = *ភាពថ្លាគ្មានមន្ទិលលាតត្រដាងឲ្យសាធារណជនបានដឹងគ្រប់គ្នា (ហ៊ីង-ថូវ៉ាក់ស៊ី និង ហ៊ាន-សាហ៊ីប ២០០៣: ៦៥៦) (ខ. តម្លា < ថ្លា + សំ. បា. ភាវ) (ពាក្យនេះ គេទើបបង្កើតប៉ុន្មានឆ្នាំនេះ តែពាក្យថា តម្លា មានប្រើតាំងពីយូរយារ ប្រើចំពោះតែចិត្តជាកុសល សូមមើល ជ.ណ. ទំព័រ ៣៣៩-៣៤០) ។*

⊙ វិសមភាព = *ភាពមិនស្មើគ្នាចំពោះមុខច្បាប់ក្នុងសង្គម (សម-ថាំង ១៩៦១: ២១៦; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ៣០១; វ. គោវិទ ១៩៦៧: ៣០៦) (សំ. បា. វិ «គ្មាន, ខ្វះ» + សំ. បា. សម «ដែលស្មើគ្នា, ប៉ុនគ្នា, ប្រហែលគ្នា; ស្រដៀងគ្នា» + សំ. បា. ភាវ) ។*

⊙ ភាពរលូន = *កិច្ចដែលប្រព្រឹត្តទៅដោយមិនមានរអាក់រអួលជាឧបសគ្គ ។*

*-កិច្ច*

⊙ អភិបាលកិច្ច = *ការគ្រប់គ្រងដឹកនាំកិច្ចធំដុំ ដូចជា ប្រទេស ខេត្ត ក្រុង ។ល។ (ហ៊ីង-ថូវ៉ាក់ស៊ី និង ហ៊ាន-សាហ៊ីប ២០០៣: ៣៣៦) (សំ. បា. អភិ «ក្រៃ, ក្រៃលែង, ក្រៃពេក, ពេកក្រៃ; ណាស់; លើសលែង; ឆ្ពោះ, ចំពោះ, ឆ្ពោះត្រង់; សង្កត់, គ្របពីលើ; ...» + សំ. បា. បាល «អ្នកការពារ, អ្នកថែរក្សា, ឆ្មាំ; គង្វាល; ស្តេច» + បា. កិច្ច (សំ. ក្ឫត្យ) «ការដែលត្រូវធ្វើ, អំពើ, ការរវល់») ។*

*-កម្ម*

⊙ វិសោធនកម្ម = *ការកែប្រែក្នុងច្បាប់ដើម្បីជាការល្បួង (សម-ថាំង ១៩៦១: ២៩; តិប-យក់ និង*

ថាវ-គន្ធ ១៩៦៧: ៣៦) (សំ. វិគោធន បា. វិសោធន «ការសម្អាត, ជម្រះ, រម្ងីងសេចក្ដី; ការល្បងមើល, ការពិនិត្យឬសាកមើលឲ្យឃើញពិត» + បា. កម្ម (សំ. កម៌) «អំពើ») ។

◎ សកលភាវូបនីយកម្ម = ការ(ធ្វើឲ្យ)កើនរីកធំឡើងសាយភាយគ្រប់ទិសទីពេញពិភពលោក (ហ៊ីង-ថូវ៉ាក់ស៊ី និង ហ៊ាន-សាហ៊ុប ២០០៣: ៣៣៣) (សំ. ឝកល, បា. សកល «ដែលទួទៅ; ទាំងអស់, ទាំងមូល, ទាំងគ្រប់» + សំ. បា. ឧបនីយ «ដែលបាននាំឲ្យទៅជិត, សំដៅ» + បា. កម្ម (សំ. កម៌) «អំពើ») ។

◎ សេវាកម្ម = ការបម្រើផ្សេងៗ ដែលមានផ្ដល់ឲ្យក្នុងវិស័យផ្សាយពាណិជ្ជកម្មទេសចរ ។ល។ ពាក្យនេះ មិនទាន់មានចុះក្នុងវចនានុក្រម ឬ សទ្ទានុក្រមទំនើប តែពាក្យសេវា មានតាំងពីទសវត្សរ៍ឆ្នាំ ១៩៥០-៦០ (សំ. បា. សេវា «ការបម្រើ» + បា. កម្ម (សំ. កម៌) «អំពើ») ។

-វិទ្យា

◎ ពត៌មានវិទ្យា = វិទ្យាសាស្ត្រដែលគណនាពត៌មានផ្សេងៗ ដោយស្វ័យប្រវត្តតាមរយៈម៉ាស៊ីនកុំព្យូទ័រ (លីដេខ្មែរ ១៩៩៨: ១៤១) (សំ. វត៌មាន បា. វត្តមាន «កាលឬសម័យដែលកំពុងប្រព្រឹត្តទៅ» > «ព្រឹត្តិការណ៍, ដំណឹងផ្សេងៗ ក្នុងបច្ចុប្បន្ន» + សំ. វិទ្យា (បា. វិជ្ជា) «សេចក្ដីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម») ។

◎ ជាតិពន្ធុវិទ្យា = សិក្សាវិភាគប្រៀបធៀបវប្បធម៌មនុស្សជាតិ មានជាអាទិ៍ រចនាសម្ព័ន្ធសង្គម ភាសាជំនឿសាសនា បច្ចេកវិទ្យា ។ល។ (សម-ថាំង ១៩៦១: ៣២៩; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ៤៧៦) (សំ. បា. ជាតិ «កំណើត; មនុស្សដែលមានសញ្ជាតិផ្សេងគ្នា» + សំ. បា. ពន្ធុ «ការទាក់ទង, ទំនាក់ទំនង; បងប្អូន, សាច់សាលោហិត; ញាតិខាងម្ដាយ; ញាតិសាច់ថ្លៃ, ញាតិពន្ធ; ដៃគូ; គូកន, ពួកម៉ាក, មិត្ត; ប្ដី» + សំ. វិទ្យា) ។

◎ នរវិទ្យា = សិក្សាពីប្រកពលក្ខណៈ ការវិវត្តផ្នែកសង្គមវប្បធម៌នៃមនុស្សជាតិ (សម-ថាំង ១៩៦១: ៣៩; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ៤៦) (សំ. បា. នរ «មនុស្ស, ជន» + សំ. វិទ្យា) ។

◎ សូរវិទ្យា = សិក្សាពីសំឡេង ការបញ្ចេញសំឡេង វិជ្ជាខាងសំឡេងរបស់មនុស្ស (លីដេខ្មែរ ១៩៩៨: ២១៥) (សំ. ក្ងាយ < សំ. ស្វរ (បា. សរ) «សំឡេង, សំឡេងលាន់ឮ» + សំ. វិទ្យា) ។

◎ ស្ថាននាមវិទ្យា, ឋាននាមវិទ្យា = សិក្សាពីឈ្មោះទីកន្លែង (សម-ថាំង ១៩៦១: ៨៣៤; តិប-យក់ និង ថាវ-គន្ធ ១៩៦៧: ១២៨១) (សំ. ស្ថាន, បា. ឋាន «ទី, កន្លែង, តំបន់, ប្រទេស, ទីតាំង, ទីតម្កល់ ។ល។» + សំ. បា. នាម «ឈ្មោះ» + សំ. វិទ្យា) ។

◎ ពលរដ្ឋវិទ្យា = សិក្សាពីសីលធម៌ វិជ្ជាខាងសីលធម៌ (លីដេខ្មែរ ១៩៩៨: ១៤២) (សំ. បា. ពល «កម្លាំង; សេនា, ទាហាន, កងទ័ព» + បា. រដ្ឋ (សំ. រាឞ្ដ្រ) «ដែន, ប្រទេស; អ្នកនៅក្នុងដែន, រាស្ត្រ, ប្រជាជន» < «ពលរបស់រដ្ឋ, ពលអាស្រ័យនៅក្នុងរដ្ឋ, ប្រជាជនទាំងប្រុសទាំងស្រី ដែលទុកជាកម្លាំងរបស់ប្រទេស» + សំ. វិទ្យា) ។ (មុខវិជ្ជានេះបានជំនួសសីលធម៌នយោបាយ ដែលមានបង្រៀនក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ក្នុងរបបសាធារណរដ្ឋប្រជាមានិតុកម្ពុជា ។)

-សាស្ត្រ

๏ អេពីដេមីសាស្ត្រ = សិក្សាអំពីរោគរាតត្បាតធំៗ (បារាំង អេពីដេមី *épidémie* «ជម្ងឺរាតត្បាត» + សំ. ឝាស្ត្រ (បា. សត្ថ) «គម្ពីរ, គម្ពីរប្រាប់វិទ្យា, គម្ពីរសាសនា; ច្បាប់, ច្បាប់ប្រដៅ, ក្បួន, តម្រា; វិជ្ជា; ការសិក្សា; ពាក្យណែនាំ, ពាក្យពន្យល់; ពាក្យបង្គាប់») ។ ពាក្យនេះមិនទាន់ឃើញមានចុះក្នុងវចនានុក្រម ឬ សទ្ទានុក្រមទំនើប ។

๏ សួរសាស្ត្រ = (សូមមើលពាក្យ សួរវិទ្យា ខាងលើ) ។

-ជន ឬ ជន-

๏ បក្ខជន = ជនដែលមានគុណសម្បត្តិ ធ្វើការច្រើន បំរើបក្ខនយោបាយ នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (បា. បក្ខ (សំ. បក្ស) «ចំណែក, ប៉ែក; ចំណែកខែ (កន្លះខែ); ចំអេងស្លាប; ពួក ។ល។» + សំ. បា. ជន «សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង») ។

๏ ជនភៀសខ្លួន = ជនដែលចាកចោលស្រុកដើមរបស់ខ្លួន ដោយហេតុផលសេដ្ឋកិច្ច ឬ នយោបាយ (លីដេខ្មែរ ១៩៩៨: ៥៣) (ក្នុងវចនានុក្រម ឬ សទ្ទានុក្រមមុន គ.ស. ១៩៧៥ គេប្រើជា អ្នកភៀសខ្លួន) ។

๏ សកម្មជន = ជនចេញមុខធ្វើសកម្មភាពខ្លាំងក្លា ដើម្បីការពារប្រយោជន៍គណៈបក្សនយោបាយណាមួយ (បា. សកម្ម «ដែលប្រកបដោយកម្ម, ដែលប្រព្រឹត្តទៅជាមួយអន្ទើដោយកម្ម; ដែលទាក់ទងដោយការងារ, ដែលនៅមិនស្ងៀម, ដែលចេះតែមានដំណើររវើករសិបជានិច្ច» + សំ. បា. ជន) ។

-ករ

๏ ពិធីករ = អ្នកសំដែងតាមកញ្ចក់ទូរទស្សន៍ ជាពិសេសសំដៅទៅលើអ្នកដឹកនាំកម្មវិធី (សំ. បា. វិធិ «បែបធ្វើ, បែបរបៀប, កិច្ចការ; ក្រឹត្តិកា» + សំ. បា. ករ «ដៃ; អ្នកធ្វើ, អ្នកបង្ក») ។

๏ ពលករ = ជនដែលមានកំឡាំងអាចចូលរួមកសាងសង្គម មាន យោធា កម្មករ និយោជិត ។ល។ ពលករ ក ៥ ជាអ្នកមានកំឡាំង ដែលគេកេណ្ឌឲ្យទៅកាប់ព្រៃនៅទល់ដែនកម្ពុជា-ថៃ នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (សំ. បា. ពល «កម្លាំង; សេនា, ទាហាន, កងទ័ព» + សំ. បា. ករ) ។

អ-

๏ អនីតិរដ្ឋ = រដ្ឋ ឬ នគរ ដែលគ្មានច្បាប់ ឬ មានច្បាប់ដែរ តែមិនអនុវត្ត ឬ មានតែមនុស្សខ្លះអនុវត្ត (សំ. បា. អ «បុព្វបទមានន័យថា មិនមែន; ពុំមាន, ខ្វះ» + សំ. បា. នីតិ «ច្បាប់; ឧបាយជាគ្រឿងណែនាំ; បែបផែន; ទំនឹមទំនៀម, ប្រពៃណី» + បា. រដ្ឋ (សំ. រាឞ្ដ្រ) «ដែន, ប្រទេស; អ្នកនៅក្នុងដែន, រាស្ត្រ, ប្រជាជន») ។

-អក, -ឥក, -ឥត (ឧទាហរណ៍ខាងក្រោមទាំងអស់នេះ មានចុះក្នុងវចនានុក្រមរបស់សម្ដេចជួន-ណាត)

◎ នាយក = អ្នកដឹកនាំ, អ្នកបង្គាប់ឬប្រើឲ្យគេធ្វើការផ្សេងៗ (សំ. បា. និ-យុជិ- «តែងតាំង» + សំ. បា. -អក «បច្ច័យសំគាល់អ្នកធ្វើ, អ្នកបង្គ, ភ្នាក់ងារ») (បើស្ត្រី ជា នាយិកា) ។

◎ យាចក = អ្នកសូមទាន, ស្មូម (សំ. បា. យាចិ- «សូម» + -អក) ។

◎ ទាយក = អ្នកឲ្យទាន, អ្នកធ្វើទាន (សំ. បា. ទា(យិ)- «ឲ្យ, ជូន; ប្រគល់» + -អក) (បើស្ត្រី ជា ទាយិកា) ។

◎ និយោជក = អ្នកដឹកនាំ, អ្នកបង្គាប់ឬប្រើឲ្យគេធ្វើការផ្សេងៗ (ជ.ណ. ទំព័រ ៥១៣) (សំ. បា. និ-យុជិ- «តែងតាំង» + -អក) ។

◎ និយោជិត = អ្នកដែលគេប្រើឲ្យធ្វើការ; កូនឈ្នួល; ភ្នាក់ងារដែលធ្វើការក្រោមបង្គាប់ចៅហ្វាយនាយក្នុងគ្រឹះស្ថានឯកជនឬក្នុងក្រសួងរាជការ (ជ.ណ. ទំព័រ ៥១៣) (សំ. បា. និ-យុជិ «តែងតាំង» + សំ. បា. -ឥត «បច្ច័យសំគាល់អ្នកដែលទទួល, ដែលរង») ។

◎ សមាជិក, បុគ្គលិក, ពុទ្ធសាសនិក ។ល។ ពាក្យទាំងនេះ មានប្រើតាំងពីយូរមកហើយ ខ្មែរគ្រប់រូបក៏ស្គាល់ដែរ ជាពាក្យមានបច្ច័យ -ឥក សម្រាប់សំដៅលើអ្នកចូលរួបរួម ។ ឧ. សមាជិក «អ្នកដែលមានអំណាចត្រូវចូលកាន់ទីប្រជុំបាន; អ្នកចូលរួមក្នុងអង្គការនយោបាយ, ក្នុងសមាគម, ក្នុងគ្រួសារ» (< សំ. សមាជ, បា. សមជ្ជ «ការប្រជុំ» + សំ. បា. -ឥក) (បើស្ត្រី ជា សមាជិកា) ។

## ៥-វិធីផ្សំពាក្យ និង ផ្គុំពាក្យ

វិធីផ្សំពាក្យនេះ ជាឫសគល់វេយ្យករណ៍របស់ភាសាខ្មែរពិតៗ ជាកេរមរតកនៃអំបូរមន-ខ្មែរ គឺបទភ្ជាប់ ដែលក្នុងនោះ មានឧបសគ្គ និង បទជ្រែក ។ បទភ្ជាប់នេះ មានប្រើតាំងពីបុរាណកាលមក ។

ឧ. ◎ រៀន> បង្រៀន (ឧបសគ្គ), សូម> ស្មូម (បទជ្រែក) ... ។

ត្រង់នេះ ខ្ញុំសូមរំលឹកបន្តិចថា កាលអំឡុងឆ្នាំ ១៩៦០ មានការប្រកែកគ្នាពីសំណាក់អ្នកប្រាជ្ញខាងភាសា ពីវិធីផ្សំពាក្យនេះ ។ អ្នកខ្លះ មានលោក ម៉ាកទីនី អ្នកស្រី កាញូនា នាំគ្នាសន្មតថា ភាសាខ្មែរលែងប្រើវិធីផ្សំពាក្យតទៅទៀតហើយ ។ ហេតុអ្វី ? ព្រោះគេពុំអាចយកពាក្យណាមួយក្នុងភាសាខ្មែរមកបង្កើតពាក្យថ្មីដោយប្រើឧបសគ្គ ឬ បទជ្រែកតាមចិត្តរបស់គេបាន ។

អ្នកស្រី ឡេវិត្ស បដិសេធការអះអាងខាងលើ ក្រើនរំឭកថា វិធីផ្សំពាក្យខ្មែរនៅតែមានគេប្រើដូចជាសម័យមុនៗ ដែរ ÷

◎ សុទ្ធ > បន្សុទ្ធ ... (ប្រើឧបសគ្គ ឧ. បន្សុទ្ធទឹក, បន្សុទ្ធមាស ...) ។

◎ ត្រង់ > តម្រង់ (ប្រើបទជ្រែក ឧ. ក្រដាសតម្រង់, តម្រង់នោម ...) ។

ការប្រើវិធីផ្សំពាក្យខ្មែរនេះតទៅទៀត គឺដោយហេតុថា ក្នុងកំលុងពាក់កណ្ដាលទសវត្សរ៍ទី ១៩៦០ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្ម បានសំរេចកំណត់ប្រើបទភ្ជាប់ ដើម្បីបង្កើតពាក្យ ដោយបដិសេធវិធីផ្គុំពាក្យកាលណាអាចធ្វើបាន ជាពិសេសពេលដែលយើងគិតគូរបញ្ចូលភាសាខ្មែរសុទ្ធ ជាភាសាជាតិ និង ភាសាផ្លូវការ មកជំនួសភាសាបារាំងក្នុងសាលារៀនខ្មែរថ្នាក់មធ្យមសិក្សា ។ គណៈកម្មាធិការខាងលើនេះ បានច្រានចោលធាតុផ្គុំ ដូចជា ÷ «ការ សេចក្ដី អ្នក ប្រដាប់» ។ល។ (ដូចមានឧទាហរណ៍ខាងក្រោមជាកស្ដុតាងស្រាប់) ទោះបីជាពាក្យថ្មីខ្លះដែលគណៈកម្មាធិការខេម-រយានកម្មបានស្នើឲ្យយកមកប្រើ មិនបានគង់វង្សក៏ដោយ ហើយគណៈកម្មាធិការខេមរយានកម្មបានបាត់បង់ទៅក្នុងឆ្នាំ ១៩៧៥ ក៏ដោយ ក៏ខេមរយានកម្មនៅតែបានជះឥទ្ធិពលដ៏សំបើមរហូតមកដល់សព្វថ្ងៃនេះ ព្រោះសព្វថ្ងៃនេះ អ្នកប្រាជ្ញ និង អ្នកកាសែតខ្មែរ នៅតែបង្កើតពាក្យថ្មីតាមវិធីប្រើបទភ្ជាប់ខ្មែរនេះជាធម្មតា ។ ឧទាហរណ៍ពាក្យថ្មីដែលគណៈកម្មាធិការខេមរយានកម្មបានស្នើ មានដូចជា ÷

| | | |
|---|---|---|
| ⊙ ចំណាត់ថ្នាក់ | មិនប្រើជា | ការចាត់ថ្នាក់ ។ |
| ⊙ តំរូវការ | មិនប្រើជា | ការត្រូវការ ។ |
| ⊙ ខ្មើតស្លាប់ | មិនប្រើជា | អ្នកកើតស្លាប់ ។ |
| ⊙ លូន | មិនប្រើជា | សត្វលូន ។ |
| ⊙ ខ្នូរ | មិនប្រើជា | ប្រដាប់កូរ ។ |

សូមបញ្ជាក់ថា នាបច្ចុប្បន្នកាល គេនៅតែឃើញមានប្រើបទភ្ជាប់ដើម្បីបង្កើតពាក្យថ្មី គ្រាន់តែការប្រើនេះ មិនបានញឹកញាប់ដូចវិធីផ្គុំពាក្យដែលនឹងលើកយកមកសិក្សាខាងក្រោម ។

ឧ. ⊙ ផ្ទុះ > បំផ្ទុះ (ប្រើឧបសគ្គ) ។

⊙ រក > របក (គំហើញ) (ប្រើបទជ្រែក) = ការរកឃើញអ្វីមួយ ពិសេសក្នុងការស្រាវជ្រាវ (ពាក្យ របកគំហើញ នេះ មានចុះក្នុងសទ្ទានុក្រមខេមរយានកម្ម គ.ស. ១៩៧៣ ទំព័រ ៩៥) ។

⊙ ថ្វា > តម្វាភាព (ប្រើបទជ្រែក) ។

វិធីផ្គុំពាក្យជាមូលភាពនៃការបង្កើតពាក្យថ្មី ដោយយកពាក្យពីរ ឬ លើសពីពីរម៉ាត់ ដាក់ភ្ជាប់គ្នា ដើម្បីបង្កើតពាក្យមួយថ្មីទៀត ។ ក្នុងវិធីផ្គុំពាក្យ អង្គធាតុនីមួយៗ មានន័យរៀងៗខ្លួន ត្រង់នេះខុសពីវិធីផ្សំពាក្យ ។

ឧ.⊙ រទេះភ្លើង ទូទឹកកក ខ្លាឃ្មុំ សៀតផ្កា ឆ្លងទន្លេ ... ។

វិធីផ្គុំពាក្យនេះ មានប្រើក្នុងភាសាខ្មែរជាយូរយារណាស់មកហើយ ហើយគេនិយមប្រើកាន់តែច្រើននាបច្ចុប្បន្ននេះ ។

ឧ. ⊙ គួចពីងពាង = សំពត់កន្ទបធ្វើពីក្រណាត់ស្ពោត មានទំរង់ដូចខោស្នាប់ ដែលក្មេងស្លៀកទ្រាប់មុនស្លៀកខោ ឬ សំពត់ធម្មតា បំណងកុំឲ្យនោម ឬ លាមកប្រឡាក់ខោ ឬ សំពត់ ។

◉ សិទ្ធិជ្រកកោននយោបាយ = *ការសុំរស់នៅទីមួយផ្សេងទៀត ដែលមិនមែនជាស្រុករបស់ខ្លួន ដោយសារតែមានការធ្វើទុក្ខបុកម្នេញ ។*

◉ គ្រុនផ្តាសាយបក្សី = *គ្រុនផ្តាសាយកាចសាហាវម្យ៉ាង ដែលផ្ទុកដោយវីរុស* H5N1 *កើតមានដំបូងពីបក្សី រួចឆ្លងមកមនុស្ស ។*

◉ លាងលុយកខ្វក់ = *បន្ថិលលុយដែលបានមកពីសកម្មភាពខុសច្បាប់ មានការជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្ម ជាដើម ឲ្យស្របច្បាប់វិញ ។*

◉ ការរើសអើងផ្លូវភេទ = *ការបែងចែក ប្រកាន់ថា ជាស្រី ឬ ប្រុស ក្នុងន័យបន្ទោកមាក់ងាយ ។*

## សេចក្តីសន្និដ្ឋាន

*ភាសាខ្មែរបច្ចុប្បន្ន ប្រើមូលភាពនៃការបង្កើតពាក្យថ្មីប្រហាក់ប្រហែលដូចដែលលោក ម៉ាកទីនី បានលើកឡើងកាលពីកន្លះសតវត្សរ៍មុន ។ អ្វីដែលផ្លាស់ប្តូរគួរឲ្យកត់សំគាល់នោះ គឺខ្មែរបន្ថយខ្ចីពាក្យភាសាបារាំង មកខ្ចីភាសាអង់គ្លេសវិញ (វិធីទី ២) ហើយកម្ចីនេះកំពុងមានទំហំកាន់តែធំទៅៗ ។ នេះសឲ្យឃើញថា មានអ្នកចេះភាសាអង់គ្លេស កើនឡើងជាលំដាប់ ។ ជួនកាល ពាក្យមកពីភាសាអង់គ្លេស ជួនគ្នានឹងពាក្យបាលីសំស្ក្រឹត ដែលធ្វើឲ្យមានការលំបាកជ្រើសរើសក្នុងការប្រើ ។ ទោះជាយ៉ាងណា ក៏ពាក្យខ្ចីពីអង់គ្លេស និង ពាក្យបាលីសំស្ក្រឹត មានតួនាទីជំនួសគ្នាទៅវិញទៅមក ។ បច្ច័យមកពីភាសាបាលី ដែលលោក ម៉ាកទីនី លើកយកមកសិក្សា នៅតែមានគេប្រើយ៉ាងទូលំទូលាយ (វិធីទី ៤) ។ សួរថា តើអាជ្ញាធរខ្មែរនានាមានប្រតិកម្មយ៉ាងណាចំពោះការវិវត្តនេះ ពិសេសចំពោះវិធីទី ២ ? បើតាមការសង្កេតមើល អាជ្ញាធរមិនបានអើពើពីការហូរចូលនៃភាសាអង់គ្លេសដ៏លើសលប់ក្នុងភាសាខ្មែរនោះទេ ពួកគេផ្ទាល់ថែមទាំងប្រើពាក្យអង់គ្លេសដោយចេតនាក្នុងច្បាប់ ឯកសាររដ្ឋបាលនានាជាផ្លូវការទៀតផង (ឈៀង-វិបុល ២០០៤) ។ ជាការពិតណាស់ ពុំមានគណៈកម្មការណាមួយ ទទួលខុសត្រូវ ត្រួតពិនិត្យការប្រើប្រាស់ពាក្យពេចន៍ខ្មែរទេ ។ នេះជាហេតុធ្វើឲ្យអ្នកកាសែត អ្នកបកប្រែ មានសេរីភាពយ៉ាងទូលំទូលាយក្នុងការបង្កើតពាក្យថ្មី ។ ភាពអនាធិបតេយ្យនេះ បានធ្វើឲ្យមានការចាប់អារម្មណ៍ពីសំណាក់អ្នកវិភាគភាសា មានលោក ឈៀង-វិបុល ដែលបានទិតៀនការប្រើប្រាស់ពាក្យអង់គ្លេសដោយលើសលប់និងគ្មានហេតុផល ។ ការសិក្សាការបង្កើតពាក្យថ្មីក្នុងភាសាខ្មែរដោយពិស្តារ អាចផ្តល់ពត៌មានសំខាន់ផ្សេងៗ ការយល់ដឹងជ្រៅជ្រះពីការផ្លាស់ប្តូរនៃសង្គមខ្មែរ ។*

*ទីបញ្ចប់ពាក្យថ្មីដែលខ្ញុំបានយកមកសិក្សាក្នុងអត្ថបទនេះ ពុំមានចុះក្នុងវចនានុក្រមខ្មែរទេ ។ នេះមិនមែនបានសេចក្តីថា ពាក្យទាំងអស់នេះ សុទ្ធតែមិនទាន់បង្កើត មិនធ្លាប់ប្រើសោះនោះទេ ។*

*ពាក្យខ្លះដូចជា* វិមជ្ឈការ ជាតិពន្ធុវិទ្យា នរវិទ្យា ... *មានចុះក្នុងវាក្យបរិវត្តន៍បារាំង-ខ្មែររបស់លោក សម-ថាំង និង ក្នុងវចនានុក្រមបារាំង-ខ្មែររបស់លោក តិប-យក់ និង លោក ថាវ-គន្ធ ដែលសុទ្ធសឹងជាពាក្យវប្បធម៌ដែលគណៈកម្មការវប្បធម៌នាសម័យនោះ ចាំបាច់ប្រែពីភាសាបារាំង ឬ បង្កើត*

*ដើម្បីប្រើម្ដងម្កាល ។ សព្វថ្ងៃ សេចក្ដីត្រូវការតម្រូវឲ្យយើងយកពាក្យទាំងនោះមកប្រើវិញ ។ ចំពោះពាក្យខ្លះទៀត ប្រហែលយើងមានប្រើម្ដងរួចមកហើយ តែត្រូវសាបរលត់ទៅវិញហើយ ដែលយើងពុំបានកត់ចំណាំទុក ។ សូមបញ្ជាក់ថា ការបោះពុម្ពលើកចុងក្រោយនៃវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ ធ្វើឡើងនៅ គ.ស. ១៩៦៧-៦៨ ។ ភាសាមានការវិវឌ្ឍផ្លាស់ប្ដូរជានិរន្តរ៍ ដូចវិស័យផ្សេងៗ ដែរ ។ តើ ៤ ទសវត្សរ៍កន្លងទៅនេះ ពាក្យខ្មែរមានការផ្លាស់ប្ដូរយ៉ាងណា ? មានកើនចំនួនប៉ុន្មាន ? កើនរបៀបណា? ពាក្យខ្លះមានប្រភពពីណា (រួមទាំងពាក្យចាស់ៗ ផង) ? បង្កើតពាក្យថ្មីឡើងដោយឈរលើមូលដ្ឋានអ្វី ? ដើម្បីឆ្លើយនឹងសំណួរខាងលើ ឲ្យបានត្រឹមត្រូវ យើងត្រូវធ្វើការសិក្សាវិភាគបន្ត កត់ត្រា ដោយប្រើពេលយូរអង្វែងដូចអារ្យប្រទេសទាំងឡាយដែលគេយកចិត្តទុកដាក់ថែរក្សា សិក្សាស្រាវជ្រាវ លើកតំកើងភាសាជាតិរបស់គេ ព្រោះថា ភាសាក៏ជាបេតិកភណ្ឌជាតិដ៏សំខាន់មួយដែរ ៕*

## កំណត់ចំណាំ

*៙ ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកស្រី យុន-សុខារី ដែលបានជួយផ្ទៀងផ្ទាត់ពាក្យថ្មីខ្លះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក មីស្ហែល-ឞុទ្ធី-អង់តែល្ម ដែលបានជួយជាគំនិតយោបល់ និង ពាក្យខ្លះដែលមានចុះបន្ថែមក្នុងសំណៅចុងក្រោយនេះ ។ ខ្ញុំក៏អរគុណផងដែរដល់អ្នកអានអនាមិក ដែលបានអានអត្ថបទនេះដោយយកចិត្តទុកដាក់ ព្រមទាំងបានចង្អុលបង្ហាញនូវចំណុចខ្សោយដែលមានក្នុងអត្ថបទនេះ ៕*

## ឯកសារពិគ្រោះ

◎ *កាញ្ចនា នាគសកុល, ឆ្នាំ ១៩៦២* [**ការសិក្សាពាក្យស្រដៀងគ្នាក្នុងភាសាថៃនិងខ្មែរ**] *និក្ខេបបទថ្នាក់បរិញ្ញា សាលាសិក្សាបូព៌ានិងអាហ្រ្វិក ឡុងដ្រ៍ ។*

KARNCHANA, Nacaskul, 1962, *A Study of Cognate Words in Thai and Cambodian*, M.A. thesis, School of Oriental and African Studies, London.

◎ *កាញ្ចនា នាគសកុល, ឆ្នាំ ១៩៧៨ «[ទំរង់ព្យាង្គ និង រូបសាស្ត្រនៃពាក្យខ្មែរ]»* [**ការសិក្សាមន-ខ្មែរ**] *លេខ ៧ ទ. ១៨៣-២០០ ។*

KARNCHANA, Nacaskul, 1978, "The Syllabic and Morphological Structure of Cambodian Words," *Mon-Khmer Studies* 7, pp. 183–200.

◎ *កេង-វ៉ាន់សាក់, ឆ្នាំ ១៩៦៤* **មូលភាពនៃការបង្កើតពាក្យថ្មី** *ភ្នំពេញ ។*

◎ *ក្លៃតុន តូម៉ាស់, ឆ្នាំ ២០០២ «[ជំរើសភាសានៃជាតិមួយ ÷ ការប្រទាញប្រទង់គ្នារវាងភាសាអង់គ្លេសនិងបារាំង នៅប្រទេសកម្ពុជា]»* [**នយោបាយភាសា**] *លេខ ១ ទ. ៣-២៥ ។*

CLAYTON, Thomas, 2002, "Language Choice in a Nation under Transition: The Struggle between English and French in Cambodia," *Language Policy* 1, pp. 3–25.

◎ *ឃីន-សុខ, ឆ្នាំ ១៩៩៩ «[ខេមរយានកម្មក្នុងវិស័យសិក្សាធិការ និង ឯករាជ្យផ្នែកវប្បធម៌ នៅប្រទេសកម្ពុជា]»* [**ព្រឹត្តប័ត្រនៃសាលាបារាំងសែសនៃចុងបូព៌ាប្រទេស**] *លេខ ៨៦ ទ. ២៩៣-៣១៩ ។*

KHIN, Sok, 1999, "La khmérisation de l'enseignement et l'indépendance culturelle au Cambodge," *Bulletin de l'École française d'Extrême-Orient* 86, pp. 293–319.

◎ ជួន-ណាត (សម្តេចព្រះសង្ឃរាជគណៈមហានិកាយ), ព.ស. ២៥១១-២៥១២ គ.ស. ១៩៦៧-១៩៦៨ **វចនានុក្រមខ្មែរ** ២ ភាគ បោះពុម្ពគ្រាទី ៥ ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ។

◎ ឈៀង-វិបុល, ឆ្នាំ ២០០៣ «ប្រត្យក្សភាពភាសានិងអក្សរសាស្ត្រខ្មែរ» **ទស្សនាវដ្តីប្រជាប្រិយ** លេខ ២៣៩១ ថ្ងៃទី ១០ ឧសភា ២០០៣ ទ. ៧២ ។

◎ ឈៀង-វិបុល, ឆ្នាំ ២០០៣ «ប្រត្យក្សភាពភាសានិងអក្សរសាស្ត្រខ្មែរ» **ទស្សនាវដ្តីប្រជាប្រិយ** លេខ ២៥១១ ថ្ងៃទី ១០ កញ្ញា ២០០៣ ទ. ៧៦ ។

◎ ឈៀង-វិបុល, ឆ្នាំ ២០០៤ «តថភាពនៃវិបត្តិភាសា និង អក្សរសាស្ត្រខ្មែរ» **ទស្សនាវដ្តីប្រជាប្រិយ** លេខ ២៧៨១ ថ្ងៃទី ១០ មិថុនា ២០០៤ ទ. ៧៤-៧៥ ។

◎ តិប-យក់ និង ថាវ-គន្ធ (សមាជិកគណៈកម្មការវប្បធម៌), គ.ស. ១៩៦៧ **វចនានុក្រមតូចបារាំង-ខ្មែរ** ភ្នំពេញ បណ្ណាគារភ្នំពេញ ។

◎ ពុទ្ធទត្ត មហាថេរ អ.ប. (អគ្គមហាបណ្ឌិត), គ.ស. ១៩៦៨ [**វចនានុក្រមសង្ខេប បាលី-អង់គ្លេស**] កូឡុំបូ ក្រុមឱសថការីនៃក្រុងកូឡុំបូ ។

BUDDHADATTA MAHĀTHERA, A. P. (Aggamahāpaṇḍita), 1968, *Concise Pāli-English Dictionary*, Colombo: The Colombo Apothecaries.

◎ ម៉ាកទីនី ហ្វ្រង់ស័រ, ឆ្នាំ ១៩៦២ «[អំពីការបង្កើតពាក្យថ្មីនាបច្ចុប្បន្នក្នុងភាសាខ្មែរ]» [**ព្រឹត្តិប័ត្រនៃសមាគមភាសាសាស្ត្រក្រុងប៉ារីស**] លេខ ៥៧.១ ទ. ១៦១-១៧៤ ។

MARTINI, François, 1962, "De la création actuelle des mots en cambodgien," *Bulletin de la société de linguistique de Paris* 57.1, pp. 161–174.

◎ ម៉ូនៀរ-វិល្លៀម្ស ម៉ូនៀរ, ឆ្នាំ ១៩៦៤ [**វចនានុក្រមសំស្ក្រឹត-អង់គ្លេស**] អុក្សហ្វ័ដ (បោះពុម្ពលើកទី ១ គ.ស. ១៨៩៩) ការផ្សាយរបស់សាកលវិទ្យាល័យអុក្សហ្វ័ដ ។

MONIER-WILLIAMS, Monier, 1964, *A Sanskrit-English Dictionary*, Oxford: Oxford University Press (1st edition: 1899).

◎ រ. គោវិទ, ឆ្នាំ ១៩៦៧ **ពាក្យថ្មីសម្រាប់អ្នកសិក្សាអក្សរសាស្ត្រខ្មែរទូទៅ** ភ្នំពេញ ការផ្សាយរបស់បណ្ណាគារ រោងពុម្ព រស្មី ។

◎ លីដេខ្មែរ, ឆ្នាំ១៩៩៨ **សទ្ទានុក្រមបច្ចេកស័ព្ទទំនើប** ភ្នំពេញ សម្ព័ន្ធភាពនិសិត្សខ្មែរពីបរទេស «លីដេខ្មែរ» ។

◎ វិទ្យាស្ថានជាតិខេមរយានកម្ម, ឆ្នាំ ១៩៧៣ **សទ្ទានុក្រមខេមរយានកម្មបារាំង-ខ្មែរ** ភ្នំពេញ ។

◎ សុខ-ផល, ឆ្នាំ ១៩៩៩ [**សូរវិទ្យានៃពាក្យកម្ចីបារាំងក្នុងភាសាខ្មែរ**] និក្ខេបបទអនុបណ្ឌិត ម៉ុងរ៉េអាល់ សកលវិទ្យាល័យម៉ុងរ៉េអាល់ ។

SOK, Phal, 1999, *La Phonologie des emprunts du français en khmer*, M.A. thesis, Montreal: Université de Montréal.

◎ សម-ថាំង, ព.ស. ២៥០៣ គ.ស. ១៩៦១ **វាក្យបរិវត្តន៍បារាំង-ខ្មែរ** (សម-ថាំង សមាជិកគណៈកម្មការវប្បធម៌ និង សាស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ជាអ្នករៀបរៀង) បោះពុម្ពលើកទី ២ ភ្នំពេញ ផ្សាយចេញពីរោងពុម្ព គីម គី បណ្ណាគារ ។

⊙ *ហ៊ីង ចូវ៉ាក់ស៊ី និង ហ៊ាង សាហ៊ីប, ឆ្នាំ ២០០៣* **វចនានុក្រមបច្ចេកសព្ទសេដ្ឋកិច្ច** *ភ្នំពេញ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (វ.ស.ហ.) នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។*

⊙ *ហេឌ្លេយ៍ រ៉ូប៊ឺត ក.ជូនិយ័រ, ឆោ គីលីន, លីម ឡាំខេង, ឃាង ហាក់លីម, និង ជុន ចេន, ឆ្នាំ ១៩៧៧* [**វចនានុក្រមអង់គ្លេស-ខ្មែរ**] *២ ភាគ វ៉ាស៊ីនតោន ឌី.ស៊ី. ក្រុមហ៊ុនបោះពុម្ពរបស់សាកលវិទ្យាល័យកាតូលិកអាមេរិក ។*

HEADLEY, Robert K. Jr., CHHOR Kylin, LIM Lam Kheng, KHEANG Lim Hak & CHUN Chen, 1977, *Cambodian-English Dictionary*, 2 vol., Washington D.C.: The Catholic University of America Press.

⊙ *ហេឌ្លេយ៍ រ៉ូប៊ឺត ក.ជូនិយ័រ, ជិម រត្ន, និង សឿម អុក, ឆ្នាំ ១៩៩៧* [**វចនានុក្រមអង់គ្លេស-ខ្មែរទំនើប**] *កិនស៊ិងតុន (រដ្ឋម៉ែរីលែន្ត) ដឹនវូឌីប្រិស្ស ។*

HEADLEY, Robert K. Jr., CHIM Rath & SOEUM Ok, 1997, *Modern Cambodian-English Dictionary*, Kensington (Maryland): Dunwoody Press.

⊙ *ឡេវិត្ស សាវេរស, ឆ្នាំ ១៩៦៧ «[ការបង្កើតពាក្យក្នុងភាសាខ្មែរទំនើប]»* [**ព្រឹត្តប័ត្រនៃសាលាជាតិនៃភាសាបូព៌ារស់**] *លេខ ៤ ទ. ៦៥-៨៤ ។*

LEWITZ, Saveros, 1967, "La dérivation en cambodgien moderne," *Revue de l'École Nationale des Langues Orientales Vivantes* 4, pp. 65–84.

⊙ *ឡេវិត្ស សាវេរស, ឆ្នាំ ១៩៦៨ «[កំណត់សំគាល់អំពីការបង្កើតពាក្យដោយប្រើបទភ្ជាប់ក្នុងភាសាខ្មែរទំនើប]»* [**ព្រឹត្តប័ត្រនៃសាលាជាតិនៃភាសាបូព៌ារស់**] *លេខ ៥ ទ. ១១៧-១២៧ ។*

LEWITZ, Saveros, 1968, "Note sur la dérivation par affixation en khmer moderne (cambodgien)," *Revue de l'École Nationale des Langues Orientales Vivantes* 5, pp. 117–127.

⊙ *អង់តែល្ម មីស្ហែល បុទ្ធី និង ប្រ៊ុយ-នុត ហេឡែន សុប្បិយ៉ា, ឆ្នាំ ២០០១* **វចនានុក្រមបារាំង-ខ្មែរ** *ប៉ារីស ឡាស៊ីយ៉ាទែក ។*

⊙ *អៀវ-កើស, ឆ្នាំ ១៩៦៧* **ភាសាខ្មែរ ការល្បងពិនិត្យដោយរកហេតុផល** *ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ ។*